គម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម
**Agricultural Value Chain Competitiveness and Safety Enhancement Project (ACSEP)**
គម្រោងលេខ: ៥០២៦៤-០០២ (ឥណទានលេខ៖ ៤០១៣-CAM (COL))

# សេចក្តីជូនដំណឹង
# ស្តីពីការជ្រើសរើស បុគ្គលិកផ្នែកអនាម័យ
(Sanitary Recruitment)

គម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម គឺជាគម្រោងដែលនឹងចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រឹងខ្សែសង្វាក់តម្លៃនៃផលិតផលកសិកម្មដែលមានលក្ខណៈប្រកួតប្រជែងមួយចំនួន មានដូចជា៖ ដំឡូងមី ផ្លែស្វាយ គ្រាប់ស្វាយចន្ទី បន្លែ និងមាន់ស្រុក នៅក្នុងខេត្តចំនួន០៦រួមមាន៖ ខេត្តកំពង់ចាម កំពង់ធំ ឧត្តមានជ័យ ព្រះវិហារ សៀមរាប និងខេត្តត្បូងឃ្មុំ។ គម្រោងនេះ នឹងផ្តល់អត្ថប្រយោជន៍ដល់សហករណ៍កសិកម្មចំនួន 230 (ប្រហែល 27,000 គ្រួសារ) និងអាជីវកម្មកសិ-ឧស្សាហកម្មចំនួន 50 នៅក្នុងតំបន់គោលដៅ។

**និយ័តករបរធនបាលកិច្ច** សូមប្រកាសជ្រើសរើស បុគ្គលិកផ្នែកអនាម័យចំនួន ០១រូប ដើម្បីបំពេញការងារជាអ្នកអនាម័យនៅក្នុងអង្គភាពអនុវត្តគម្រោង។

**១. បេក្ខជនទាំងពីរភេទត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម៖**

| | |
|---|---|
| **សញ្ជាតិ** | ជាជនជាតិខ្មែរ |
| **ភាសា** | ភាសាខ្មែរ (អាចសរសេរបាន) |
| **ការអប់រំ** | យ៉ាងហោចបានបញ្ចប់ថ្នាក់ចំណេះដឹងទូទៅភាសាខ្មែរ |
| **បទពិសោធន៍** | - មានបទពិសោធន៍យ៉ាងហោចណាស់ ១ឆ្នាំ ទាក់ទងនឹងការងារផ្នែកអនាម័យ<br>- មានបទពិសោធន៍ធ្វើការជាមួយស្ថាប័នរដ្ឋ វិស័យឯកជន ឬសហគ្រាសផ្សេងៗ<br>- មានបទពិសោធន៍ខ្លះៗទាក់ទងនឹងការគ្រប់គ្រងសម្ភារអនាម័យ<br>- មានបទពិសោធន៍ខ្លះៗនូវក្នុងកិច្ចប្រាស្រ័យទាក់ទង និងពិធីការ។ |
| **សមត្ថភាព** | - មានសុខភាពល្អ សុភាពរាបសារ ស្មោះត្រង់ និងមានចរិកល្អ ស្លូតបូត<br>- ចេះអាន ចេះសរសេរ និងឆាប់យល់<br>- មានភាពរួសរាយ រាក់ទាក់ និងមានឆន្ទៈក្នុងការបំពេញការងារ<br>- មានពេលវេលាគ្រប់គ្រាន់បំពេញការងារពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ<br>- អាចធ្វើដំណើរទៅទីតាំងអនុវត្តគម្រោង។ |
| **តម្រូវការផ្សេងៗ** | - ត្រូវមានមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន<br>- មានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៤០ឆ្នាំ<br>- ផ្តល់អាទិភាពដល់ស្ត្រី |

**២.ភារកិច្ចទទួលខុសត្រូវ**

- បំពេញភារកិច្ចជាអ្នកទទួលបន្ទុកផ្នែកអនាម័យទូទៅ នៅក្នុងអង្គភាពអនុវត្តគម្រោង ACSEP Output1
- រៀបចំ ចាត់ចែង គ្រប់គ្រង ថែទាំ និងប្រើប្រាស់សម្ភារអនាម័យ របស់អង្គភាពអោយបានល្អ
- រៀបចំសំណើសម្ភារគាំទ្រសកម្មភាពអនាម័យជូនដល់ផ្នែករដ្ឋបាលទទួលបន្ទុក
- ត្រូវប្រាកដថាពេលដែលចេញពីធ្វើការ បង្អួច ទ្វារ ម៉ាស៊ីនត្រជាក់ និងឧបករណ៍អគ្គីសនីផ្សេងៗ ត្រូវបានបិទជានិច្ច
- រៀបចំសំអាតអនាម័យជាប្រចាំក្នុងអង្គភាព និងតាមទីតាំងអនុវត្តគម្រោង ពេលមានតម្រូវការ
- បន្ទប់ទឹកត្រូវប្រាកដថាស្អាត និងមានផាសុខភាពជានិច្ច
- ពេលមានភ្ញៀវមកត្រូវរៀបចំកន្លែងទទួលភ្ញៀវ និងដាក់ទឹកជូនភ្ញៀវ
- ពេលទំនេរអាចជួយការងារផ្សេងៗដែលអាចធ្វើទៅបាន។

**៣. លក្ខខណ្ឌនៃកិច្ចសន្យា និងប្រាក់ឧបត្ថម្ភ៖**

- រយៈពេល៣ខែដំបូងចាត់ទុកជាការសាកល្បងការងារ
- កិច្ចសន្យានឹងត្រូវបញ្ចប់នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៣ ហើយអាចត្រូវបានវាយតម្លៃ និងបន្តកិច្ចសន្យាទៅឆ្នាំបន្ទាប់ទៀត ដោយផ្អែកលើតម្រូវការជាក់ស្តែង
- បុគ្គលិកផ្នែកអនាម័យនឹងទទួលបានប្រាក់ខែចំនួន ១៨០ ដុល្លារ (មួយរយប៉ែតសិបដុល្លារ) ក្នុង១ខែ និងប្រាក់ឧបត្ថម្ភបេសកកម្មផ្សេងៗ ក្នុងករណីទៅបំពេញការងារតាមបណ្តាខេត្តគោលដៅ។

**៤. លក្ខខណ្ឌតម្រូវដាក់ពាក្យសុំចូលបម្រើការងារ**

- បំពេញពាក្យសុំចូលបម្រើការងារចំនួន ០១ច្បាប់ (ពាក្យសុំអាចរកបាននូវផ្នែករដ្ឋបាល អង្គភាពអនុវត្តគម្រោង)
- ប្រវត្តិរូបសង្ខេបចំនួន ០១ច្បាប់ ដោយភ្ជាប់នូវលេខទូរស័ព្ទ សម្រាប់ទំនាក់ទំនង
- ច្បាប់ចម្លងឯកសារយោងចំនួន ០១ច្បាប់ (សៀវភៅគ្រួសារ អត្តសញ្ញាណប័ណ្ណ ឬសញ្ញាប័ត្របញ្ជាក់ការសិក្សា)

**៥. កាលបរិច្ឆេទ និងទីកន្លែងទទួលពាក្យ**

- កាលបរិច្ឆេទចាប់ទទួលពាក្យចាប់ពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០២២
- កាលបរិច្ឆេទឈប់ទទួលពាក្យចាប់ពីថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ១៨:០០នាទី
- ទីតាំងដាក់ពាក្យគឺនៅអង្គភាពអនុវត្តគម្រោង ACSEP រៀងរាល់ម៉ោងធ្វើការ ចាប់ពីថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ។

ថ្ងៃសុក្រ ១កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២

**ប្រធានគម្រោង**

**សុខ ដារ៉ា**